ស្វែងយល់អំពីជំនួយ **ទាំងអស់** របស់អ្នក។

# ផ្តោតទៅលើ៖ មធ្យាបាយធ្វើដំណើរ

សុខភាពរបស់អ្នកមានសារៈសំខាន់ចំពោះយើង ដែលនេះជាមូលហេតុដែលជំនួយរបស់អ្នករួមមានទាំងជំនួយក្នុងការធ្វើដំណើរទៅមកពេទ្យ និងសេវាកម្មដែលត្រូវបានគេផ្តល់ជូនតាមរយៈគម្រោងសុខភាពរដ្ឋអូរិហ្គិន (Oregon Health Plan- OHP)។ ប្រសិនបើអ្នកមិនមានមធ្យាបាយណាមួយដើម្បីទៅជួបពេទ្យតាមការណាត់ទេ នោះដៃគូ **Ride to Care** របស់យើង អាចជូនអ្នកទៅទីនោះបាន។

## មានវិធីបីយ៉ាងដើម្បីទទួលសុំណាត់ឡានជូន

**បុគ្គលិកផ្តល់សេវាកម្មបំរើអតិថិជន Ride to Care នឹងធ្វើការជាមួយអ្នក ដើម្បីស្វែងរកជម្រើសដែលសមស្របបំផុត និងចំណាយតិចបំផុត ដើម្បីបំពេញតាមតម្រូវការរបស់អ្នក៖**

### ឡានឬរថភ្លើងក្រុងសាធារណៈ

យើងផ្តល់នូវសំបុត្រជិះឡានឬរថភ្លើងប្រចាំថ្ងៃ ឬប្រចាំខែ។ យើងនឹងពិភាក្សាអំពីការណាត់ពេលរបស់អ្នក ហើយសម្រេចថាតើសំបុត្រសំរាប់ជិះមួយថ្ងៃឬប្រចាំខែគឺសមជាងគេសំរាប់អ្នកដើម្បីទៅពេទ្យតាមការកំណត់របស់អ្នក។

### សំណង

យើងចេញថ្លៃធ្វើដំណើរគិតជាម៉ាយល៍ទៅ និងមកជួបពេទ្យ។ អ្នកអាចបើកបរដោយខ្លួនឯង ឬរកអ្នកផ្សេងអាចបើកបរជូនអ្នកបាន។ សូមបោះពុម្ពបែបបទយល់ព្រមអោយជូនទៅជួបពេទ្យនៅ **ridetocare.com** ហើយសុំឱ្យបុគ្គលិកពេទ្យរបស់អ្នកចុះហត្ថលេខាលើបែបបទនោះ។ ការទូទាត់សងថ្លៃត្រូវបានគេបញ្ចូលទៅក្នុងកាតឥណពន្ធបង់ប្រាក់ជាមុន។

### ការជូនទៅពេទ្យតាមយានយន្ត

យើងអាចកំណត់ពេលជិះឡានជាឯកជន និងជិះរួមគ្នាបាន។ ដោយផ្អែកលើតម្រូវការផ្នែកពេទ្យរបស់អ្នក យើងអាចបញ្ជូនឡានធម្មតា ឡានដែលមានរទេះពិការ ឡានដាក់រទេះរុញ ឬរថយន្តមិនមែនសំរាប់សង្គ្រោះបន្ទាន់អោយអ្នកបាន។

អ្នកមានសិទ្ធិស្នើសុំជិះនៅថ្ងៃដែលត្រូវទៅពេទ្យ ឬមុនមួយថ្ងៃបាន។ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើអ្នកស្នើមកយើងឆាប់រហ័សពេក ហើយតម្រូវការសុំជិះមានច្រើន នោះយើងផ្តល់អាទិភាពដល់សំណើណាដែលត្រូវទៅពេទ្យជាបន្ទាន់។

សូមទូរស័ព្ទទៅ **Ride to Care** ដើម្បីស្វែងយល់បន្ថែមតាមរយៈ:
លេខ **855-321-4899**
**ឬ TTY 711**

**ទូរស័ព្ទទៅ Ride to Care តាមលេខ 855-321-4899 ឬ TTY 711** ដើម្បីដឹងថាតើសេវាកម្មណាដែលសាកសមសម្រាប់អ្នក។ រាល់ពេលដែលអ្នកទូរស័ព្ទមក យើងនឹងសួរសំណួរអំពីអ្នក និង ការធ្វើដំណើរប្រភេទណាដែលអ្នកកំពុងស្នើសុំ។ នៅពេលណាដែលអាចធ្វើទៅបាន សូមទូរស័ព្ទមកយើងយ៉ាងហោចណាស់ពីរថ្ងៃ មុនពេលណាត់ជួបពេទ្យ ដើម្បីពិភាក្សា និងរៀបចំពេលធ្វើដំណើរជូនអ្នក។ អ្នកអាចសុំកំណត់ពេលជិះរហូតដល់ 90 ថ្ងៃមុនពេលទៅពេទ្យបាន។

**ប្រសិនបើអ្នកមានចម្ងល់ផ្សេងៗ សូមទូរស័ព្ទទៅផ្នែកសេវាបំរើអតិថិជន CareOregon តាមរយៈលេខ 800-224-4840។**

**careoregon.org**

health share
Health Share of Oregon

CareOregon®

## សូមស្គាល់អំពី CareOregon

# ការដឹកជញ្ជូនគឺជាសេវាកម្មដែលផ្តល់ដោយ CareOregon ដែលជាគម្រោងសុខភាពមេឌីខេដរបស់អ្នក។ ចង់ដឹងបន្ថែមអំពីយើងនៅទីនេះ។

នៅពេលដែលគេនិយាយអំពីមេឌីខេដនៅរដ្ឋអូរិហ្គិន អ្នកប្រហែលជាអាចឮគេនិយាយឈ្មោះ ឬអក្សរផ្សេងៗគ្នាជាច្រើន។ នោះដោយសារតែមានអង្គការជាច្រើនដែលពាក់ព័ន្ធក្នុងរឿងនេះ ដើម្បីឱ្យប្រាកដថាអ្នកទទួលបានការថែទាំដែលអ្នកសមនឹងទទួលបាន។ តើអ្នកអាចយល់បានដោយរបៀបណា?

## វាជួយដល់អ្នកទទួលជំនួយមេឌីខេដក្នុងរដ្ឋអូរិហ្គិនដូចជាពីរ៉ាមីត

**អាជ្ញាធរសុខភាពរដ្ឋអូរិហ្គិន (OHA)** គ្រប់គ្រងកម្មវិធីមេឌីខេដ សម្រាប់រដ្ឋអូរិហ្គិនទាំងមូល ដែលត្រូវបានគេហៅថាគម្រោងសុខភាពរដ្ឋអូរិហ្គិន (OHP) ។

**ចំណែកសុខភាពនៃរដ្ឋអូរិហ្គិន (HSO)** គឺជាអ្វីដែលគេហៅថា អង្គការផ្តល់កិច្ចគាំពារដែលមានការសម្របសម្រួល (CCO)។ ចំណែកសុខភាពនៃរដ្ឋអូរិហ្គិន ធ្វើការក្រោម OHA ដើម្បីបម្រើសមាជិក OHP នៅក្នុងតំបន់ខោនទីបី។

**CareOregon** គឺជាអ្នកផ្តល់សេវាធានារ៉ាប់រងមួយក្នុងចំណោមអ្នកផ្តល់សេវាធានារ៉ាប់រងជាច្រើននៅក្នុងតំបន់ទាំងបីខោនទីនោះ ដែលជួយ CCO ក្នុងការផ្តល់កិច្ចគាំពារ។ សេវាកម្មដឹកជញ្ជូនត្រូវបានផ្តល់ជូនពី CareOregon ។

**គ្រូពេទ្យចំបង (PCP) របស់អ្នក** អាចជាវេជ្ជបណ្ឌិត គ្រូពេទ្យគិលានុបដ្ឋាយិកា ជំនួយការគ្រូពេទ្យ ឬគ្រូពេទ្យប្រើថ្នាំធម្មជាតិ។ ពួកគេសម្របសម្រួលកិច្ចគាំពាររបស់អ្នកជាមួយ CareOregon និងសមាជិកក្រុមគ្រូពេទ្យផ្សេងទៀត ដូចជាទន្តបណ្ឌិត អ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត ឱសថការី និងពេទ្យដទៃទៀត។

### CareOregon ផ្តល់សេវាកម្មបែបនេះសម្រាប់សមាជិកមេឌីខេដ (OHP)៖

- គ្រូពេទ្យសុខភាពរាងកាយ
- គ្រូពេទ្យសុខភាពផ្លូវចិត្ត
- ការព្យាបាលផ្តាច់គ្រឿងញៀន
- គ្រូពេទ្យធ្មេញ
- មេឌីឃែរតាមរយៈ CareOregon Advantage
- កិច្ចគាំពារពេលដំណាក់កាលចុងក្រោយ និងកិច្ចគាំពារអ្នកជំងឺតាមរយៈគ្រូពេទ្យផ្តល់សេវាទូរសព្ទតាមផ្ទះ (Housecall Providers)

### អ្នកក៏នឹងអាចប្រើប្រាស់សេវាកម្មសំខាន់ៗដូចជា៖

- ការសម្របសម្រួលកិច្ចគាំពារ
- ឱសថស្ថាន
- កិច្ចគាំពារមុនពេលសម្រាលកូន និងថែទារក
- ជម្រើសធ្វើដំណើរ
- សេវាកម្មអ្នកបកប្រែភាសា
- កិច្ចគាំពារសង្គ្រោះបន្ទាន់ និងមើលជាបន្ទាន់

**careoregon.org**

### មានសំណួរអ្វី?

តើអ្នកចង់ដឹងបន្ថែមទេ? សូមទូរស័ព្ទទៅ**បុគ្គលិកសេវាកម្មបំរើអតិថិជន**របស់យើង ដែលពេញចិត្តនឹងជួយអ្នក តាមរយៈលេខ **800-224-4840** ឬផ្ញើសារសុវត្ថិភាពមកយើងតាមរយៈ *careoregon.org/portal*

អ្នកអាចទទួលបានសំបុត្រនេះជាភាសាផ្សេងទៀត ការបោះពុម្ពជាអក្សរធំៗ អក្សរសំរាប់មនុស្សពិការភ្នែក ឬជាទម្រង់ដែលអ្នកចង់បាន។ អ្នកក៏អាចស្នើសុំរកអ្នកបកប្រែភាសាផងដែរ។ ជំនួយនេះគឺឥតគិតថ្លៃទេ។ ចូរទូរស័ព្ទទៅលេខ 800-224-4840 ឬ TTY 711។